ពិភពរឿងនិទាន
The World of Stories

# បក្សីលៀងអារក្ស

# Birds Feasting Demon



សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the source of knowledge

កាលដើមឡើយ មានមេព្រាបមួយកំពុងមានទុក្ខជាទម្ងន់។ ព្រាបនេះពងមិនចេញសោះ ព្រោះពងរបស់វាធំខុសពីធម្មតា។ ម្ល៉ោះហើយ ព្រាបចេះតែថ្ងូររហ៊ឹះៗ ដង្ហោយហៅឱ្យគេមកជួយសង្គ្រោះខ្លួន។

In the ancient time, there was a pigeon that was profoundly sad. She could not lay an egg, for it was bigger than the normal egg. As a result, the pigeon had always been cooing for help.



ព្រាបយំថ្ងូរយ៉ាងនេះ ធ្វើឱ្យផ្អើលដល់សត្វដទៃ ទៀតមកជួយឈូឆរ ហើយក៏កើតចលាចលនាំគ្នា មកមើលជម្ងឺព្រាប។ ព្រោះហេតុនេះហើយ បានជា ព្រាបយំថ្ងូររហ៊ឹះៗ ជាប់រហូតមកដល់សព្វថ្ងៃនេះ។

Her coo surprised many other birds to come and cure her illness crowdedly. Accordingly, the pigeons have always cooed since then.



ក្នុងបណ្ដាអ្នកដែលមកជួយនោះ មានសត្វខ្លះក៏ជួយឈឺឆ្អាល តែមានសត្វខ្លះទៀតបែរជាមកបញ្ឈឺបន្សេកបន់ផ្ដន្ទាចង់ឱ្យមេព្រាបនោះស្លាប់ទៅវិញ។ ហេតុនេះហើយបានជាមានសម្រែកសត្វប្លែកៗពីគ្នាតាមភាសារបស់វា។



Among the coming birds, some came to show sympathy; while others came to hurt her feelings, wishing her to pass away. Therefore, there were various sounds of different species of birds, speaking their language respectively.





ក្អែកស្រែកថា ងាប់ឥឡូវ! ងាប់ឥឡូវ!។ កូនមាន់ស្រែកថា ចបៗ ចបៗ។ មានន័យថា ឱ្យគេរកចបបម្រុងកប់ខ្មោចព្រាប។ ព្រោះព្រាបនេះវានឹងស្លាប់ឥឡូវហើយ។ ទាស្រែកបន្ថែមតាមក្រោយមាន់ថា កាប់ៗ កាប់ៗ។ ព្រោះថា បើព្រាបស្លាប់ហើយ មាន់ឱ្យគេរកចបកាប់ដីកប់ព្រាបតែម្តងទៅ។



The crow cawed "Ngorb Eilov, Ngorb Eilov" (die now), while little chicken clucked "Chorb, Chorb (hoe!hoe!)" It meant that they needed hoes to bury the pigeon's corpse because she was going to die. Ducks quacked after the little chickens, "Kab!kab, Kab!kab" (dig), that was if the pigeon had died, the chicken told others to dig a hole and bury the pigeon's dead body right away.



ក្រៅពីសត្វដែលផ្ដន្ទាឱ្យព្រាបស្លាប់ នៅមានសត្វដែលជួយសង្គ្រោះព្រាបជាច្រើនទៀត។ នៅពេលនោះ សត្វលលកស្រែកថា រកគ្រូ! រកគ្រូ!។ ហើយសត្វដទៃទៀតក៏ជំនុំគ្នាថា ត្រូវតែទៅរករូបមេមត់ឱ្យមកជួយសង្គ្រោះជីវិតមេព្រាបជាបន្ទាន់។



Besides the birds cursing the pigeon to death, there were many other birds coming for help. Meanwhile, the dove shouted, "Rork Krou! Rork Krou!"(Find the midwife), and other birds discussed that they hade to find a witch to save the pigeon's life immediately.



ប៉ុន្តែរូបមេមត់នោះនៅឆ្ងាយណាស់ ហើយពេល
នេះជារដូវវស្សាមានទឹកជោរជន់ លិចវាលល្ហល្ហាច
ផង។ បើធ្វើដំណើរទៅ ទាល់តែរកទូកក្តារ ច្រវ៉ា
ចែវទើបបាន ម្ល៉ោះហើយពួកអ្នកជួយសង្គ្រោះទាំង
នោះម្មីម្មាស្រែកកកោកកកាករកនេះរកនោះលាន់
ទ្រហឹង។



But the witch was far away, and it was also the raining session with flooding. In order to go, they needed a boat and an oar. Thus the saviors rashly shouted in the loud voice to find "this" to find "that".



អាអូតស្រែកថា ទូក១! ទូក១! មាន់ទឹកស្រែកថា ច្រវា! ច្រវា!។ ប្រវឹក និង ស្មោញ នាំគ្នាបាចទឹកចេញពីទូកព្រុស្សរ ខ្វក់១! ខ្វក់១! ។ រួចហើយ គេក៏ចេញទូកនាំមេព្រាបដែលជាអ្នកជម្ងឺនោះ ឆ្ពោះទៅលំនៅមៀមជារូបមេមត់។



Aout (a kind of bird) shouted, "Touk! Touk! " (boat), while moorhen clucked, "Chrova! Chrova!"(oar), and the teal and darter threw the water from the boat sounding, " Kwouk! Kwouk!"(The sound of water throwing). Then, they put sickened pigeon on the boat to leave for the residence of  wood owl that served as a witch.



លុះពេលព្រលប់ទើបពួកគេទៅដល់
លំនៅសត្វមៀមរូបមេមត់នោះ។ គេក៏យក
សត្វទីទុយធ្វើជាស្នំសម្រាប់និយាយលួងលោម
អង្វររូបមេមត់។ បណ្តាសត្វដទៃទៀតដែលមាន
សម្រែកផ្សេងៗគ្នា ក៏ប្រជុំគ្នាធ្វើជាវង់ភ្លេងអារក្ស
មួយវង់ ដើម្បីបញ្ឆាន់រូបមេមត់នោះ។ សត្វត្លុម
ធ្វើស្គរ សារិកាកែវធ្វើទ្រ ល្វាចេកធ្វើប៉ី ត្រសេះ
វាយក្រាប និង កន្ទេបជាអ្នកច្រៀង។



They reached the wood owl's house in the evening. Then, the owl acted as the concubine to plea the wood owl for help. Other animals whose sounds were different come together to play an orchestra to feast the witch wood owl. The watercock served as a drum player, myna as the tro player, magpie as piper, wood pecker as the Krap player and drongo as singer.



លុះនាំគ្នាធ្វើត្រាប់បទភ្លេងបានមួយចប់ហើយ ទីទុយជាស្នំ ចាប់ផ្ដើមសួរឡើងថា ទីទុយពើតពើង! កូនយើងជាទេ? ទីទុយពើតពើង! កូនយើងជាទេ?។

After imitating a song, the owl served as the concubine started to ask, "Tituy Pertperng! Koun Yoeung Chea Te! Tituy Pertperng! Koun Yoeung Chea Te!" (The wood owl, our child is better!)



មៀមដែលជារូបមេមត់ ពុំមានស្តីថាអ្វីសោះ រឹតតែបើកភ្នែកធំៗ។ លុះទីទុយនៅតែសួរដដែលៗពេក មៀមក៏ឆ្លើយតែពីរម៉ាត់ថា លៀង! លៀង! ឮដូច្នេះ គ្រលីងគ្រលោងក៏ស្រែកឡើងថា ជាក៏លៀង មិនជាក៏លៀង! ជាក៏លៀង មិនជាក៏លៀង។

The wood owl didn't say anything and only tried to open her eyes wider and wider. Because of questioning again and again from the owl, the wood owl answered only two words "Lieng! Lieng! ". Hearing like that, Kroling Kroloung (kind of bird) shouted "Chea kor Lieng! Min chea Kor Lieng! (Recovery is to feast, or not recovery is also to feast) "



លុះចប់ពិធីបញ្ចាន់រូបមេមត់ហើយ សត្វព្រាបក៏បានជាសះស្បើយឡើងវិញ។ គ្រាន់តែមេព្រាបប្រឹងបន្តិច ក៏ស្រាប់តែចេញពងដ៏ធំមួយយ៉ាងឆាប់រហ័ស។ សត្វទាំងអស់ត្រេកអរជាខ្លាំង ក៏នាំគ្នាវិលមកកាន់កំពង់ជ ដើម្បីចម្លងមេព្រាបត្រលប់មកកន្លែងខ្លួនវិញ។ លុះមកដល់កំពង់រកទូកពុំឃើញ ក៏បង្ហូកហៅរកគ្នាក្រែងមានអ្នកណាយកទូកទៅអុំលេង ស្រាប់តែមានសត្វមួយស្រែកឆ្លើយពីត្រើយម្ខាងមកថា គូក២ គូក២។ ហើយគេនាំគ្នាដាក់ឈ្មោះសត្វនោះថា សត្វគូករហូតមកដល់សព្វថ្ងៃ។



When the traditional witch feast was ended, the pigeon was getting recovered and she only made a little effort; a big egg quickly came out. All the animals were happily indeed. They went back to the port and took the pigeon back to her nest. When they reached the port, they didn't see the boat. They called for one to another to find out if any one rowed the boat. Suddenly, an animal from the other side made sound "Kouk! Kouk! ". Then, it was named "Kouk" from that time up to now.



ចំណែកសត្វក្អែកដែលជាសត្វផ្តន្ទា ចង់ឱ្យព្រាប ស្លាប់ តែបែរជាមិនស្លាប់វិញនោះ ព្រោះបានទីទុយ មៀម គូក ជាអ្នកជួយយកអាសាព្រាប ក្អែកក៏ប្រកាន់ ស្អប់សត្វទាំងនេះ។ ពេលបានឃើញសត្វទាំងនេះ កាលណា វាតែងតែព្រួតដេញចឹកមៀម ទីទុយ គូក មិនឱ្យនៅជិតវាឡើយ។ **ចប់**

## ជួយគ្នាក្នុងគ្រាមានអាសន្ន

As for the crow who wished the pigeon to die, but she didn't because of the assistance from owl, wood owl, and "Kouk". That was why the crow hated those animals. Whenever the crows see those animals, they always chase to peck them away. **The End**

